# ឯកសារទស្សនទាន
# សិក្ខាសាលាស្តីពី "រួបរួមគ្នាដើម្បីប្រព័ន្ធគាំពារសង្គមប្រកបដោយបរិយាបន្ននៅកម្ពុជា"
# កាលបរិច្ឆេទ៖ ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២៣
# (វេលាម៉ោង ០៨.៣០ ដល់១២.០០នាទីថ្ងៃត្រង់)
# ទីកន្លែង៖ សូមជម្រាបជូនពេលក្រោយ
# (សេចក្តីព្រាង)

## សាវតានៃកម្មវិធី៖

ការរីករាលដាលនៃជំងឺកូវីដ១៩ (COVID-19) បានជះឥទ្ធិពលយ៉ាងខ្លាំងដល់សុខភាពសាធារណៈទូទាំងពិភពលោក ជាពិសេសនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ គិតត្រឹមខែមេសា ឆ្នាំ២០២៣ មានករណីឆ្លងចំនួន ៧៦២.២៧លានករណី និងមានអ្នកស្លាប់ចំនួន ៦.៨៩ លាននាក់ នៅទូទាំងពិភពលោក[1]។ នាទសវត្សរ៍ចុងក្រោយនេះ មិនត្រឹមតែមានជំងឺរាតត្បាត **COVID-19** ប៉ុណ្ណោះទេ ប៉ុន្តែក៏មានជំងឺរាតត្បាតជាសាកលផ្សេងទៀតផងដែរ ដូចជាជំងឺ **SARS, Ebola** និងជំងឺផ្សេងៗទៀត។ ជាងនេះទៅទៀត ពិភពលោកនឹងទទួលរងនូវវិបត្តិអាកាសធាតុ ដែលចាត់ទុកថាជាវិបត្តិសុខភាពផងដែរ។ តួយ៉ាង ការបំពុលខ្យល់បានសម្លាប់មនុស្សប្រមាណ ៧លាននាក់ជារៀងរាល់ឆ្នាំ ខណៈដែលការប្រែប្រួលអាកាសធាតុធ្វើឱ្យមានកង្វះអាហារូបត្ថម្ភកាន់តែធ្ងន់ធ្ងរ និងជំរុញឱ្យមានការរីករាលដាលនៃជំងឺឆ្លង[2]។ លើសពីនេះ នៅក្នុងសតវត្សនេះ មនុស្សកាន់តែច្រើនកំពុងប្រឈមមុខនឹងជំងឺដែលប៉ះពាល់ដល់ប្រព័ន្ធឈាម (Cardiovascular) ដែលជាកត្តារួមចំណែកធ្វើឱ្យខូចខាតសុខភាព និងខាតបង់សេដ្ឋកិច្ច ហើយជាបន្ទុកដល់ប្រព័ន្ធសុខាភិបាល[3]។

ដូច្នេះហើយ វាមានភាពចាំបាច់ណាស់ក្នុងការពង្រឹងប្រព័ន្ធសុខាភិបាល និងក្របខណ្ឌគាំពារសង្គមនៅកម្រិត ជាតិ ដើម្បីធ្វើឱ្យសង្គមមួយដែលមានភាពធន់ និងមានសមត្ថភាពអាចដោះស្រាយបញ្ហាជំងឺរាតត្បាត និងវិបត្តិសុខភាពនាពេលអនាគត។ នៅឆ្នាំ២០២០ អង្គការសុខភាពពិភពលោក (WHO) បានចេញផ្សាយបញ្ជីនៃបញ្ហាប្រឈមផ្នែកសុខភាពសាកលបន្ទាន់[4] ហើយបានអំពាវនាវឱ្យរដ្ឋាភិបាលទូទាំងពិភពលោកវិភាជន៍ ឬបែងចែកថវិកាបន្ថែមទៀត ដើម្បីដោះស្រាយភាពខ្វះចន្លោះនៃប្រព័ន្ធសុខាភិបាល និងហេដ្ឋារចនាសម្ព័ន្ធសុខាភិបាល ក៏ដូចជាផ្តល់ការគាំទ្រដល់ប្រទេសដែលងាយរងគ្រោះបំផុត។ នៅកម្រិតពិភពលោក WHO កំពុងធ្វើការដើម្បីលើកកម្ពស់ការគ្របដណ្តប់លើការថែទាំសុខភាព

[1] https://www.jica.go.jp/Resource/english/news/field/2023/20230518_11.html
[2] https://www.who.int/news-room/photo-story/photo-story-detail/urgent-health-challenges-for-the-next-decade
[3] https://www.healthdata.org/news-events/insights-blog/acting-data/11-global-health-issues-watch-2023-according-ihme-experts
[4] https://www.who.int/news-room/photo-story/photo-story-detail/urgent-health-challenges-for-the-next-decade

ជាសាកល[5] និងផ្តល់ជំនួយបច្ចេកទេសដល់ប្រទេសដែលមានប្រព័ន្ធសុខាភិបាលទន់ខ្សោយ។ ការងារនេះបានស្របទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) ដែលជារបៀបវារៈសាកលឆ្នាំ២០៣០។

យោងតាមអង្គការអន្តរជាតិខាងការងារ (ILO) ប្រជាជនភាគច្រើនក្នុងពិភពលោក (៥៥ ភាគរយ) ខ្វះការទទួលបានកិច្ចគាំពារសង្គម ហើយប្រហែល ១៦ភាគរយ ទទួលបានការគាំពារដោយផ្នែកប៉ុណ្ណោះ។ នេះបង្ហាញថាមានការវិនិយោគតិចតួចលើផ្នែកថែទាំសុខភាព ភាពអត់ការងារធ្វើ ប្រាក់សោធននិវត្តន៍សម្រាប់មនុស្សចាស់ ឬកុមារ និងប្រាក់ឧបត្ថម្ភដល់ជនមានពិការភាពជាដើម។ ការវិនិយោគតិចតួចក្នុងប្រព័ន្ធគាំពារសង្គមបានធ្វើឱ្យប្រជាជន រងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយជំងឺរាតត្បាត និងជំរុញឱ្យពួកគេធ្លាក់ចូលទៅក្នុងភាពក្រីក្រ។ ដោយហេតុផលនេះហើយ អង្គការអន្តរជាតិខាងការងារ បានអំពាវនាវឱ្យអង្គការសហប្រជាជាតិបង្កើតមូលនិធិសាកលសម្រាប់កិច្ចគាំពារសង្គម ដើម្បីផ្តល់ការគាំទ្រជាអន្តរជាតិដល់ប្រទេសទទួលជំនួយ ដើម្បីពង្រឹងភាពធន់ ដោយការកសាងប្រព័ន្ធគាំពារសង្គមជាសាកល[6]។

នៅក្នុងបរិបទរបស់ប្រទេសកម្ពុជា ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម (NSPF) ផ្តោតលើសសរស្តម្ភសំខាន់ចំនួនពីរគឺ ប្រព័ន្ធជំនួយសង្គម និងប្រព័ន្ធសន្តិសុខសង្គម។ ក្របខណ្ឌជាតិនេះ គឺជាឧបករណ៍គោលនយោបាយសម្រាប់កាត់បន្ថយ និងការបង្ការនូវភាពក្រីក្រ ភាពងាយរងគ្រោះ និងវិសមភាពនៅក្នុងប្រទេសកម្ពុជា[7] ដែលស្របតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (CSDGs) និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិកម្ពុជា (NSDP)។ លើសពីនេះ ប្រព័ន្ធគាំពារសង្គម និងការពង្រីកសេវាថែទាំសុខភាពឆ្ពោះទៅរកការគ្របដណ្តប់សុខភាពជាសាកល ត្រូវបានបញ្ចូលក្នុងកម្មវិធីគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជានិតិកាលទី៧។ ការប្តេជ្ញាចិត្តនេះ ត្រូវការការវិនិយោគ ឆន្ទៈនយោបាយដ៏រឹងមាំ រួមបញ្ចូលទាំងគោលនយោបាយផ្សេងៗ និងប្រព័ន្ធត្រួតពិនិត្យ ប្រកបដោយប្រសិទ្ធភាព ជាពិសេសការចូលរួមពីភាគីពាក់ព័ន្ធសំខាន់ៗ។

គិតត្រឹមខែសីហា ឆ្នាំ២០២៣ បេឡាជាតិសន្តិសុខសង្គមមានសមាជិកជាង ៣លាននាក់[8] (ស្ត្រី ១.៧លាននាក់) ខណៈដែលកម្មវិធីជំនួយសង្គមបានផ្តល់ទៅដល់ប្រជាពលរដ្ឋប្រហែល ៦៩០.០០០គ្រួសារ និងបុគ្គលចំនួន ២.៧លាននាក់ នៅចន្លោះឆ្នាំ២០២០ និង២០២១[9]។ តួលេខទាំងនេះបង្ហាញពីភាពប្រសើរឡើងគួរឱ្យកត់សម្គាល់ក្នុងប្រព័ន្ធសន្តិសុខសង្គម និងប្រព័ន្ធជំនួយសង្គមនៅកម្ពុជា ដែលរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ និងវិសមភាព។ ទោះជាយ៉ាងណាក៏ដោយ កិច្ចគាំពារសង្គមនៅកម្ពុជានៅតែមិនទាន់អនុវត្តន៍បានគ្រប់គ្រាន់ ដោយសារការបែងចែកថវិកាជាតិសម្រាប់ប្រព័ន្ធគាំពារសង្គមមានកម្រិត ភាពខ្វះចន្លោះក្នុងការគ្រប់គ្រងទិន្នន័យ និងយន្តការត្រួតពិនិត្យនិងវាយតម្លៃ ដើម្បីធ្វើឱ្យប្រសើរឡើងនូវគណនេយ្យភាព តម្លាភាព និងការផ្តល់សេវាប្រកបដោយបរិយាបន្ន។ ជាងនេះទៅទៀត កង្វះ

---

[5] Universal health coverage (UHC) means that all people have access to the full range of quality health services they need, when and where they need them, without financial hardship.
[6] https://www.ohchr.org/en/press-releases/2021/06/world-needs-prepare-next-crisis-setting-global-fund-social-protection-now-un
[7] National Social Protection Policy Framework 2016-2025.
[8] http://www.nssf.gov.kh/employment-injury-scheme-2/registration/
[9] VNR 2023 Cambodia Report.


www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009
#9-11, Street. 476,
Toul Tompoung 1, Chamkamorn
P.O. Box 885, Phnom Penh,
Cambodia

សហថាមពល (Synergy) រវាងតួអង្គសំខាន់ៗ ដូចជារាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងអង្គការសង្គមស៊ីវិល ក៏ជាឧបសគ្គដល់ការសម្រេចបាននូវកិច្ចគាំពារសង្គមប្រកបដោយបរិយាបន្នផងដែរ។

ក្នុងការរួមចំណែកដោះស្រាយបញ្ហាប្រឈម និងគម្លាតនាពេលកន្លងមក យើងឃើញថា រាជរដ្ឋាភិបាលកម្ពុជា បានបើកទូលាយក្នុងការធ្វើការជាមួយដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងអង្គការសង្គមស៊ីវិល ដើម្បីបង្កើននូវប្រសិទ្ធភាព និងប្រព័ន្ធគាំពារសង្គមប្រកបដោយបរិយាប័ន្ន តាមរយៈការជំរុញឱ្យមានកិច្ចសន្ទនាសង្គម និងចែករំលែកការអនុវត្តល្អ និងបញ្ហាប្រឈមនៃការអនុវត្តន៍គោលនយោបាយពាក់ព័ន្ធនានា។

ការចូលរួមប្រកបដោយអត្ថន័យពីភាគីពាក់ព័ន្ធទាំងអស់ គឺចាំបាច់ដើម្បីសម្រេចបាននូវតម្លាភាព បរិយាបន្ន និង និរន្តរភាពនៃកិច្ចគាំពារសង្គម។ វាមានសារៈសំខាន់ណាស់ដែលភាគីពាក់ព័ន្ធទាំងអស់អាចយល់គ្នាទៅវិញទៅមក ចែករំលែកនូវបញ្ហាប្រឈម និងការរៀនសូត្រពីការអនុវត្តគោលនយោបាយ និងផ្តល់ការគាំទ្រដល់អ្នកទទួលផលពីប្រព័ន្ធគាំពារសង្គម ដើម្បីស្វែងរកឱកាសសម្រាប់កិច្ចសហប្រតិបត្តិការ និងការរួបរួមគ្នាកាន់តែប្រសើរឡើងនាពេលអនាគត។ អាស្រ័យហេតុនេះ អង្គការ គ.ស.ក នឹងរៀបចំសិក្ខាសាលាស្តីពី "**រួបរួមគ្នាដើម្បីប្រព័ន្ធគាំពារសង្គមប្រកបដោយបរិយាបន្ន នៅកម្ពុជា**" ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២៣ នៅរាជធានីភ្នំពេញ ក្នុងគោលបំណងផ្តល់វេទិកាសម្រាប់អ្នកទទួលផលក្នុងការចែករំលែកបទពិសោធន៍ និងកង្វល់អំពីការទទួលសេវាថែទាំសុខភាព និងសេវាគាំពារសង្គមផ្សេងទៀត ដល់អ្នកធ្វើសេចក្តីសម្រេចចិត្ត និងរៀបចំកិច្ចសន្ទនារវាងរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល ដើម្បីពិភាក្សាអំពីបញ្ហាប្រឈម ឱកាស និងវិធីឆ្ពោះទៅរកកិច្ចគាំពារសង្គមប្រកបដោយចីរភាព និងបរិយាបន្ននៅកម្ពុជា។

## គោលបំណង៖

- ដើម្បីផ្តល់ឱកាសសម្រាប់អ្នកចូលរួមក្នុងការស្វែងយល់បន្ថែមទៀតអំពីគោលនយោបាយនិងកម្មវិធីដែលមានស្រាប់ពាក់ព័ន្ធនឹងកិច្ចគាំពារសង្គម និងគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលអាណត្តិទី៧ ចំពោះការគ្របដណ្តប់សុខភាពជាសាកល និងព្រមទាំងការពង្រីកការគ្របដណ្តប់ប្រព័ន្ធសន្តិសុខសង្គម និងប្រព័ន្ធជំនួយសង្គម។
- ដើម្បីផ្តល់វេទិកាសម្រាប់អ្នកទទួលផល និងក្រុមងាយរងគ្រោះ ដើម្បីលើកឡើងពីបញ្ហាប្រឈម និងគម្លាតក្នុងការទទួលបានរបបសន្តិសុខសង្គម និងរបបជំនួយសង្គម ព្រមទាំងចំណុចដែលត្រូវកែលម្អដល់ភាគីពាក់ព័ន្ធសំខាន់ៗ។
- ដើម្បីលើកកម្ពស់ការយល់គ្នាទៅវិញទៅមក និងភាពជាដៃគូក្នុងចំណោមភាគីពាក់ព័ន្ធ រួមមានភ្នាក់ងាររាជរដ្ឋាភិបាល វិស័យឯកជន ដៃគូអភិវឌ្ឍ និងអង្គការសង្គមស៊ីវិលដើម្បីបង្កើនកិច្ចខិតខំប្រឹងប្រែង និងផ្តល់ធនធានសម្រាប់ការអភិវឌ្ឍ និងជំរុញឱ្យគោលនយោបាយគាំពារសង្គមមានបរិយាបន្ន។


www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009
#9-11, Street. 476,
Toul Tompoung 1, Chamkamorn
P.O. Box 885, Phnom Penh,
Cambodia
Accountability GPP Symbol of Trust 23/02/2023 22/02/2028

## សមាសភាពអ្នកចូលរួម៖

សិក្ខាសាលានេះបានរំពឹងថានឹងមានអ្នកចូលរួមប្រមាណ ៨០នាក់ ដែលជាសមាជិករបស់អង្គការ គសក, អង្គការដៃគូ, អង្គការសហគមន៍មូលដ្ឋាន (CBOs), ក្រុមងាយរងគ្រោះ, មន្ត្រីរាជរដ្ឋាភិបាល, ដៃគូអភិវឌ្ឍ និងភាគីពាក់ព័ន្ធផ្សេងទៀត។

## របៀបវារៈកម្មវិធី៖

| ម៉ោង | របៀបវារៈសំខាន់ៗ | អ្នកសម្របសម្រួល |
|---|---|---|
| ៨:០០ - ៨:៣០ | ការអញ្ជើញមកដល់ និងចុះវត្តមានរបស់អ្នកចូលរួម | ក្រុមការងារ គសក |
| ៨:៣០ - ៨:៣៥ | គោរពភ្លេងជាតិ និងជម្រាបជូនអង្គសិក្ខាសាលានូវគោលបំណងនៃកម្មវិធី | អ្នកស្រី **ប្រាក់ កែវគង្គា** អ្នកជំនាញផ្នែកច្បាប់នៃអង្គការ គសក |
| ៨:៣៥ - ៨:៥០ | កិច្ចស្វាគមន៍ និងប្រកាសបើកកម្មវិធី | អ្នកស្រី **ស៊ិន ពុទ្ធារី** នាយិកាប្រតិបត្តិនៃអង្គការ គសក |
| ៨:៥០ - ៩:០០ | ការចាក់បញ្ចាំងវីដេអូករណីសិក្សាស្តីពី "**ស្ថានភាពនៃការថែទាំសុខភាពរបស់និស្សិតជនជាតិដើមភាគតិច និងសហគមន៍ជនងាយរងគ្រោះដែលធ្វើផ្លាស់ទីមកធ្វើការ និងរស់នៅក្នុងរាជធានីភ្នំពេញ**" | លោក **អ៊ុំ សុធា** មន្ត្រីទំនាក់ទំនងអង្គការ គសក |
| ៩:០០ - ៩:២០ | បទបង្ហាញស្តីពី **គោលការណ៍ទូទៅនៃក្របខ័ណ្ឌជាតិគាំពារសង្គម** | តំណាងពីក្រុមប្រឹក្សាជាតិគាំពារសង្គម |
| ៩:២០ - ៩:៥០ | ការពិភាក្សាក្រុមរបស់អ្នកចូលរួម៖ **បទពិសោធន៍ និងបញ្ហាប្រឈមក្នុងការទទួលសេវាគាំពារសង្គម និងសេវាសុខភាពសាធារណៈ**<br>ក្រុម១៖ ក្រុមជនជាតិដើមភាគតិច<br>ក្រុម២៖ ក្រុមអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងសហគមន៍ក្រីក្រ<br>ក្រុម៣៖ ក្រុមមនុស្សចាស់<br>ក្រុម៤៖ ក្រុមជនមានពិការភាព<br>ក្រុម៥៖ ក្រុមកុមារ និងយុវជន | អ្នកសម្របសម្រួល៖ អ្នកស្រី **ប្រាក់ កែវគង្គា** អ្នកជំនាញផ្នែកច្បាប់នៃអង្គការ គសក |

| | | |
|---|---|---|
| | ការបង្ហាញលទ្ធផលពិភាក្សាពីក្រុមនីមួយៗ | |
| ៩:៥០ - ១០:០០ | ដើរទស្សនាការតាំងពិពណ៌អំពី "**គោលដៅអភិវឌ្ឍប្រកបដោយចីរភាព ពាក់ព័ន្ធនឹងកិច្ចគាំពារសង្គម និងការគ្របដណ្តប់សុខភាពសាកល**" | លោក **ផេង សេង** ជំនួយការផ្នែកគោលនយោបាយ ច្បាប់ និងតស៊ូមតិនៃអ្នកស្រី **ប្រាក់ កែវគង្គា** អ្នកជំនាញផ្នែកច្បាប់នៃអង្គការ គសក និងយុវទូតសម្រាប់គោលដៅអភិវឌ្ឍន៍ប្រកបដោយចិរភាព |
| ១០:០០ - ១០:២០ | ថតរូបជាក្រុម និងសម្រាកអាហារសម្រន់ | ក្រុមការងារផ្នែកទំនាក់ទំនងនៃអង្គការ គសក និងអ្នកចូលរួមទាំងអស់គ្នា |
| ១០:២០ - ១១:៤៥ | កិច្ចពិភាក្សាស្តីពី "**ការរួបរួមគ្នាដើម្បីប្រព័ន្ធគាំពារសង្គមប្រកបដោយបរិយាបន្ននៅកម្ពុជា**"<br><br>សំនួរ និងចម្លើយ និងធាតុចូលពីអ្នកចូលរួម | អ្នកសម្របសម្រួល៖ លោក **នី វាសនា** មន្ត្រីគោលនយោបាយ ច្បាប់ និងតស៊ូមតិនៃអង្គការ គសក<br>វាគ្មិន៖<br>- តំណាងពីក្រុមប្រឹក្សាជាតិគាំពារសង្គម (បញ្ជាក់ពេលក្រោយ)<br>- តំណាងពី បសស (បញ្ជាក់ពេលក្រោយ)<br>- តំណាងពី SP4All (បញ្ជាក់ពេលក្រោយ)<br>- តំណាងពីកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (បញ្ជាក់ពេលក្រោយ) |
| ១១:៤៥ - ១២:០០ | ប្រកាសបិទកម្មវិធី | អ្នកស្រី **ស៊ិន ពុទ្ធារី** នាយិកាប្រតិបត្តិនៃអង្គការ គសក |

**Note:** *The meeting's languages will be available in Khmer and English. The organizer reserves the right to alter the agenda depending on time constraints and the availability of speakers. Some of the pictures and key ideas will be quoted and shared in public through the organizers' social media and website.* http://www.ccc-cambodia.org/en/resources/event-archives; www.facebook.com/CCCsince1990 www.facebook.com/CCCsince1990 www.youtube.com/CCCambodia



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street. 476,
Toul Tompoung 1, Chamkamorn
P.O. Box 885, Phnom Penh,
Cambodia

Accountability គណនេយ្យភាព
GPP
23/02/2023 22/02/2028
Symbol of Trust